ប្រការ ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

***

**អនុក្រឹត្យលេខ ៧៥ អនក្រ.បក**

***ស្តីពីការផ្ទេរផលលាភជាទិកា***

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១១៩៤

- បានឃើញព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០
- តាមសំណើររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ ._ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១៦០ លានរៀល (មួយរយហុកសិបលានរៀលគត់) ពីជំពូក ៩១ ( ចំណាយមិនបានគ្រោងទុក ) ចំណាយមិនទាន់បែងចែកមកជំពូក ១១ ( ចំណាយទំនិញការផ្គត់ផ្គង់ សំភារៈ និង ការជួសជុលតូច ) របស់ក្រសួងធនធានទឹក និង ឧតុនិយម សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ។

មាត្រា ២ ._ ឥណទានថវិកា ក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ចំណាយលើការងារទប់ស្កាត់ទឹកជំនន់នៅរាជធានីភ្នំពេញ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីធនធានទឹក និងឧតុនិយមត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៣៦២ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

★★★

## រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា